**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

លេខ: ៥៣៦.អនោប.ក.ទអអ

# សេចក្តីណែនាំ

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ សូមជម្រាបដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ជ្រាបថាៈ ការប្រើប្រាស់ហត្ថពលករបរទេស គឺស្ថិតក្នុងដែនអនុវត្តដែលមានចែងក្នុងមាត្រា ២៦១ នៃច្បាប់ស្តីពីការងារ និងមាត្រា១៩, ៣១, ៣២, ៣៣, ៣៦ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ព្រមទាំងប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការធ្វើអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា លេខៈ២៦៦២ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

កន្លងមកអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ បានចាត់តាំងក្រុមចំរុះអធិការកិច្ចហត្ថពលកម្មបរទេស ចុះត្រួតពិនិត្យតាមសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ពលករបរទេសនៅទូទាំងប្រទេស បានសង្កេតឃើញថា ជាទូទៅជនបរទេសដែលកំពុងប្រកបមុខរបរ និងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានគោរព និងអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ បានយ៉ាងល្អប្រសើរ ពលករបរទេសទាំងនោះមានលិខិតឆ្លងដែនសុពលភាពត្រឹមត្រូវ មានប្រភេទទិដ្ឋាការសំរាប់ធ្វើការ និងមានប័ណ្ណការងារ ។ ក៏ប៉ុន្តែនៅមានសហគ្រាស គ្រឹះស្ថាន និងពលករបរទេសមួយចំនួនតូចពុំទាន់យកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចអោយ ត្រឹមត្រូវតាមច្បាប់កំណត់នៅឡើយ ទោះបីជាក្រុមអធិការកិច្ចបានណែនាំធ្វើកិច្ចសន្យាទុករយៈពេលអោយទៅបំពេញបែបបទបានស្របច្បាប់ជាញឹកញាប់ណាស់ទៅហើយក្តី ។

ឆ្លើយតបទៅនឹងសភាការណ៍ជាក់ស្តែងខាងលើនេះ សំដៅអោយម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន និងពលករបរទេសបានស្វែងយល់ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តបានត្រឹមត្រូវតាមច្បាប់ ។ អគ្គនាយកដ្ឋានអន្តោប្រវេសន៍សូមជូនដំណឹងដល់គ្រប់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងរាល់ពលករបរទេសដែលមានបំណង និងកំពុងប្រកបមុខរបរ ឬធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា៖

១.ត្រូវប្រញាប់បំពេញបែបបទអោយបានគ្រប់គ្រាន់តាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍។

២.ជាទូទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍នឹងចុះត្រួតពិនិត្យតាមគោលដៅ សហគ្រាស គ្រឹះស្ថាននានាក្នុងពេលរកឃើញថាពលករបរទេសណាម្នាក់ដែលកំពុងប្រកបមុខរបរ ឬធ្វើការគ្មានលិខិតឆ្លងដែនដែលមានសុពលភាពត្រឹមត្រូវ គ្មានប្រភេទទិដ្ឋាការសំរាប់ធ្វើការ គ្មានប័ណ្ណការងារ ក្រុមចំរុះអធិការកិច្ចហត្ថពលកម្មបរទេស នឹងធ្វើការផាកពិន័យតាមច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ពលករបរទេសនឹងធ្វើការស្វែងយល់ពីច្បាប់ និងកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាព ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥
**អគ្គនាយកអន្តោប្រវេសន៍**

នាយឧត្តមសេនីយ៍ ស៊ុខ ផល